**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខ :** ៥១៧.សជណ.សរ

រាជធានីភ្នំពេញ, ថ្ងៃទី៣ខែ ៣ឆ្នាំ២០១៤

# សេចក្ដីជូនដំណឹង

## ស្ដីពី

## លទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៧

## នាថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៤

កាលពីថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៤ វេលាម៉ោង ៨:០០ នាទីព្រឹក នៅវិមានសន្តិភាព មានបើកវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្រោមប្រធានបទ **"សហគមន៍សេដ្ឋកិច្ចអាស៊ាន២០១៥-កាលានុវត្តភាព និងការប្រឈមចំពោះកម្ពុជា"** ។ អង្គវេទិកាដែលចាត់ទុកថា ជាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបើកទូលាយ ដោយមានការចូលរួមពីសមាជិករាជរដ្ឋាភិបាល អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ តំណាងក្រសួង-ស្ថាប័នមានសមត្ថកិច្ច អង្គទូតនានាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា អង្គការអន្តរជាតិ និងវិនិយោគិនជាតិ និងអន្តរជាតិ មានទិសដៅស្ដាប់របាយការណ៍ ស្ដីពីសកម្មភាពអភិវឌ្ឍន៍ផ្នែកឯកជន ធុរកិច្ច និងការវិនិយោគនាពេលកន្លងមក និងពិនិត្យដោះស្រាយនូវបញ្ហាជាកង្វល់មួយចំនួនរបស់ធុរជន និងវិនិយោគិន ដែលបាននិងកំពុងធ្វើសកម្មភាពបណ្ដាក់ទុននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្នុងចន្លោះពីវេទិកាលើកទី១៦ មកលើកទី១៧នេះ ក្រុមការងារទាំង១០របស់រាជរដ្ឋាភិបាល និងផ្នែកឯកជនបានខិតខំដោះស្រាយនូវរាល់បញ្ហា និងកង្វល់របស់ធុរជន និងវិនិយោគិនបានមួយចំនួនធំរួចហើយ។ ចំពោះបញ្ហា និងសំណូមពរមួយចំនួនដែលក្រុមការងារពុំអាចដោះស្រាយបាននោះ ត្រូវបានលើកមកពិភាក្សាក្នុងវេទិកាលើកទី១៧នេះ ដើម្បីប្រមុខរាជរដ្ឋាភិបាលពិនិត្យដោះស្រាយ និងផ្ដល់អនុសាសន៍ណែនាំបន្ថែម តាមករណីជាក់ស្ដែង។

ក្រោយពីបានស្តាប់របាយការណ៍សង្ខេបរបស់ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាអ្នកសម្របសម្រួលវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ស្តីពីសកម្មភាព និងលទ្ធផលនៃការពិភាក្សាដោះស្រាយបញ្ហា និងសំណូមពររបស់ក្រុមការងារផ្នែកឯកជនទាំង១០ និងក្រោយពីបានស្តាប់មតិរបស់សហប្រធានក្រុមការងារផ្នែកឯកជនទាំង១០រួចមក សម្តេចតេជោនាយករដ្ឋមន្ត្រីបានយល់ថា មានការចាំបាច់តម្រូវឱ្យមានការបញ្ជាក់បំភ្លឺលើប្រធានបទចំនួន៣ គឺ ÷

**១-បញ្ហាពន្ធដារ÷**

ក្នុងក្របខ័ណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងពន្ធដារ គឺរដ្ឋពុំមានគោលការណ៍បង្កើតបន្ទុកពន្ធថ្មី ឬដំឡើងពន្ធបន្ថែមដល់ប្រជាជន និងធុរជន ក្នុងគោលដៅបង្កើនចំណូលថវិកាជាតិនោះទេ ពោលគឺរាជរដ្ឋាភិបាលនឹងផ្តោតលើការពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ជាពិសេសការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធ និងការគេចវេសពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់ ព្រមទាំងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូលទាំងក្នុងផ្នែកគយ និងផ្នែកពន្ធដារ។ រាជរដ្ឋាភិបាលនឹងបន្តចាត់វិធានការជំរុញកិច្ចសម្រួលពាណិជ្ជកម្មបន្ថែមទៀត តាមរយៈការកែលម្អក្របខ័ណ្ឌគោលនយោបាយ និងបទប្បញ្ញត្តិច្បាប់ ព្រមទាំងនីតិវិធីផ្សេងៗ ឱ្យកាន់តែមានភាពសាមញ្ញ និងខ្លីជាងមុន ដើម្បីបន្តកែលម្អបរិស្ថានវិនិយោគ និងធុរកិច្ចឱ្យកាន់តែមានភាពអនុគ្រោះ និងទាក់ទាញ ព្រមទាំងដើម្បីជួយសម្រួលដល់ប្រតិបត្តិការអាជីវកម្ម និងសកម្មភាពនាំចេញ-នាំចូលគ្រប់ប្រភេទឱ្យកាន់តែមានលក្ខណៈងាយស្រួល និងកាន់តែមានភាពប្រកួតប្រជែងប្រសើរជាងមុន។

រាជរដ្ឋាភិបាលនៅតែមានសុឆន្ទៈខ្ពស់ ក្នុងការបន្តពិនិត្យ និងពិចារណាជួយដោះស្រាយ និងសម្រួលបន្ថែមទៀត ក្នុងករណីរាជរដ្ឋាភិបាលពិនិត្យឃើញថា នៅមានបន្ទុកពន្ធ ឬនីតិវិធីមួយចំនួនលែងមានលក្ខណៈសមស្រប ហើយមានភាពចាំបាច់ និងសមរម្យ។ ទន្ទឹមនឹងនេះ វិស័យឯកជនត្រូវបន្តខិតខំកសាង និងអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួន ហើយត្រូវបោះបង់ចោលនូវទម្លាប់ចាស់ ដែលកន្លងមកតែងតែស្នើសុំការលើកទឹកចិត្តផ្នែកពន្ធដារពីរដ្ឋ មិនចេះឈប់នេះចេញ ហើយជំនួសមកវិញនូវការផ្តល់ព័ត៌មាន និងអនុសាសន៍នានាជូនរាជរដ្ឋាភិបាល ពិសេសពាក់ព័ន្ធនឹងការដោះស្រាយបញ្ហាប្រឈមនានា និងចាប់យកឱកាសល្អៗដែលកើតចេញពីសមាហរណ-កម្មសេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ ព្រមទាំងពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា នៅក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក។

**២- បញ្ហាថ្លៃអគ្គិសនីសម្រាប់ផ្គត់ផ្គង់ជូនសហគ្រាសពាណិជ្ជកម្ម និងឧស្សាហកម្ម ÷**

គោលដៅសំខាន់នៃការអភិវឌ្ឍវិស័យអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺធ្វើយ៉ាងណាឱ្យមានការផ្គត់ផ្គង់ថាមពលអគ្គិសនីគ្រប់គ្រាន់ សម្រាប់បម្រើសេចក្តីត្រូវការប្រើប្រាស់ទូទាំងប្រទេស តាមរយៈថ្លៃមួយសមរម្យដែលអាចធ្វើឱ្យការផលិត ការផ្គត់ផ្គង់ និងការប្រើប្រាស់អគ្គិសនី ប្រព្រឹត្តទៅប្រកបដោយគុណភាព ប្រសិទ្ធភាព ចីរភាព និងតម្លាភាព ដើម្បីសម្រួលដល់ការវិនិយោគ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ក្នុងស្ថានភាពរបស់ប្រទេសកម្ពុជា ដែលត្រូវការអភិវឌ្ឍបន្ថែមជាបន្តបន្ទាប់ ដើម្បីឱ្យមានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ផង និងមានបណ្តាញផ្គត់ផ្គង់គ្រប់ទីកន្លែងផង ថ្លៃអគ្គិសនីនៅពេលបច្ចុប្បន្ន ត្រូវតែឆ្លុះបញ្ចាំងតាមស្ថានភាពជាក់ស្តែងនៃថ្លៃដើមអគ្គិសនី ពុំអាចចំណុះលើគោលនយោបាយឧបត្ថម្ភធនពីរដ្ឋបានឡើយ។ ការ

កំណត់ថ្លៃដើមអគ្គិសនីនៅកម្ពុជា បានផ្អែកលើគោលការណ៍សំខាន់ៗគឺ ថ្លៃអគ្គិសនីនាំចូល បូកពន្ធនាំចូល៧% បូកនឹងអាករលើតម្លៃបន្ថែម VAT ១០% បង្កើតបានជាថ្លៃនាំចូល ដែលត្រូវយកមកលាយគ្នាជាមួយអគ្គិសនីផលិតក្នុងស្រុក ដើម្បីបង្កើតបានជាថ្លៃមធ្យមទូទៅមួយ ហើយថ្លៃនេះត្រូវយកមកបូកជាមួយនឹងថ្លៃខ្សែបណ្តាញបញ្ជូនចំនួន ២សេនដុល្លារអាមេរិកថែមទៀត។

**៣- បញ្ហាទំនាក់ទំនងវិជ្ជាជីវៈ÷**

រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ និងបានផ្តល់ភាពអនុគ្រោះជាច្រើន ដើម្បីទាក់ទាញវិនិយោគ និងបង្កើតឱកាសការងារជូនប្រជាពលរដ្ឋ។ ព្រមជាមួយនេះ រាជរដ្ឋាភិបាលក៏បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយស្តីពីការការពារសិទ្ធិរបស់កម្មករ និយោជិត ដោយចាត់ទុកដូចជាការអនុវត្តសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជាផងដែរ។ គោលនយោបាយនេះ បានបង្កើតរោងចក្រសហគ្រាសជាច្រើន បានផ្តល់ការងាររាប់លានកន្លែង និងបង្កើតមុខរបរថ្មីៗជូនប្រជាពលរដ្ឋ ដើម្បីកែលម្អជីវភាព។

រាជរដ្ឋាភិបាលបានបញ្ជាក់ជាថ្មីម្តងទៀតថា ការអនុវត្តសិទ្ធិសេរីភាពនៃការទាមទារទាំងឡាយត្រូវធ្វើឱ្យបានត្រឹមត្រូវតាមច្បាប់ អំពើល្មើសច្បាប់មិនអាចអត់ឱនតទៅទៀតបានឡើយ។ រាជរដ្ឋាភិបាលការពារដាច់ខាតចំពោះផលប្រយោជន៍យុវជន ប៉ុន្តែមិនគាំទ្រសកម្មភាពទាំងឡាយណា ដែលយកអនាគតយុវជនកម្ពុជា ជាការសាកល្បង ជាល្បែងភ្នាល់ និងជាដើមទុនក្នុងការសម្រេចនូវមហិច្ឆតានយោបាយរបស់មនុស្សមួយក្រុមតូចណាមួយនោះទេ។ រាជរដ្ឋាភិបាល ដាច់ខាតមិនទុកឱ្យក្រុមណាមួយយកកម្មករ និយោជិតធ្វើជាឈ្នាន់នយោបាយ និងយករោងចក្រ សហគ្រាស ធ្វើជាចំណាប់ខ្មាំងរបស់ក្រុមខ្លួនជាដាច់ខាត ពោលគឺរាជរដ្ឋាភិបាល ត្រូវការពារផ្លែផ្កាដែលបានមកពីការលះបង់ចំណូលថវិការដ្ឋដ៏ច្រើនសន្ធឹកសន្ធាប់ នោះគឺការងារសម្រាប់កម្មករ និយោជិត ។

ការបង្កើនប្រាក់ឈ្នួលប្រចាំខែ គឺត្រូវផ្សារភ្ជាប់នឹងសមត្ថភាពផលិតរបស់កម្មករ និយោជិត។ នៅពេលណាដែលរោងចក្រមានផលិតភាពខ្ពស់ លទ្ធភាពប្រកួតប្រជែងរបស់គេនៅលើទីផ្សារនឹងមានកាន់តែខ្លាំង។ នៅពេលដែលផលិតផលរបស់រោងចក្រមានភាពប្រកួតប្រជែង ចំណូលរបស់ក្រុមហ៊ុននឹងមានកំណើន។ ជាលទ្ធផលក្រុមហ៊ុននឹងមានលទ្ធភាពជូនប្រាក់ឈ្នួលខ្ពស់ដល់កម្មករ និយោជិត។ ដូច្នេះ ការលើកកម្ពស់ផលិតភាព មិនគ្រាន់តែជួយកម្ពុជាឱ្យមានសមត្ថភាពប្រកួតប្រជែងក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ ខាងមុខនេះទេ ក៏ប៉ុន្តែនឹងផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់កម្មករ និយោជិត។

ដើម្បីដោះស្រាយនូវបញ្ហាចម្បងទាំង៣ខាងលើ និងបញ្ហានានាមួយចំនួនទៀត រាជរដ្ឋាភិបាលនឹងជំរុញបង្កើនល្បឿននៃការអនុវត្តកំណែទម្រង់ស៊ីជម្រៅសំខាន់ៗរបស់ខ្លួន ដោយផ្តោតលើចំណុចជាអាទិភាពមួយចំនួនរួមមាន÷ ទី១-ការលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម ទី២-ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទី៣- ការសម្របសម្រួលឱ្យមានភាពស៊ីសង្វាក់គ្នារវាងវិស័យអប់រំ វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបន្តអភិវឌ្ឍធនធានមនុស្សឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងទី៤-ការបន្តជំរុញធ្វើពិពិធកម្មប្រភពនៃកំណើនសេដ្ឋកិច្ចឱ្យមានប្រសិទ្ធភាព តាមរយៈការអនុម័ត និងជំរុញ "គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម"។

ចំពោះការដាក់ចេញនូវ "គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម" រាជរដ្ឋាភិបាលមានបំណងលើកស្ទួយផលិតកម្ម បង្កើនភាពប្រកួតប្រជែង និងច្បាមយកតម្លៃបន្ថែមឱ្យបានកាន់តែច្រើននៅក្នុងវិស័យសំខាន់ៗ ដែលមានស្រាប់រួមមានវិស័យកសិកម្ម ឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ ព្រមទាំងលើកស្ទួយប្រភេទ ឧស្សាហកម្មថ្មីៗ ដែលមានសក្តានុពលរីកលូតលាស់ និងខិតខំបង្កើនឧត្តមភាពប្រៀបធៀបថ្មីក្នុងវិស័យឧស្សាហកម្មកម្ពុជា។

ឆ្លើយតបទៅនឹងសំណូមពរនានារបស់ក្រុមការងារទាំង១០របស់ផ្នែកឯកជន កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបើកទូលាយបានសម្រេចដូចខាងក្រោម÷

**១-ផ្នែកទេសចរណ៍**

- ក្រសួងទេសចរណ៍ និងអគ្គស្នងការនគរបាលជាតិត្រូវ÷
    + ខិតខំរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីបន្ថែមបញ្ជរនគរបាលអន្តោប្រវេសន៍នៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ក៏ដូចជានៅតាមច្រកទ្វារសំខាន់ៗផ្សេងទៀត ដើម្បីសម្រួលដល់កំណើនភ្ញៀវទេសចរ ដែលឆ្លងកាត់ច្រកទ្វារទាំងនោះ។
    + រៀបចំបែបបទ និងនីតិវិធី ដើម្បីចាត់តាំងមន្ត្រីនគរបាលអន្តោប្រវេសន៍ ផ្តល់ទិដ្ឋាការជូនភ្ញៀវទេសចរនៅលើយន្តហោះតែម្តង ចំពោះក្រុមហ៊ុនយន្តហោះណាដែលផ្តល់លទ្ធភាពឱ្យមន្ត្រីនគរបាលបំពេញភារកិច្ចបែបនេះ ដូចដែលក្រុមហ៊ុនយន្តហោះរបស់ជប៉ុន បានអនុវត្តរួចហើយជាមួយប្រទេសឥណ្ឌូនេស៊ី ។
    + ខិតខំរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីពង្រឹងសុវត្ថិភាព និងសន្តិសុខ នៅតាមទីប្រជុំជន និងតំបន់ដែលមានទេសចរច្រើន។
- ក្រសួងទេសចរណ៍ និងក្រសួងបរិស្ថាន សហការជាមួយអាជ្ញាធរដែនដី ត្រូវរៀបចំយន្តការអចិន្ត្រៃយ៍មួយ ដើម្បីឆ្ពោះទៅអនុវត្តកម្ពុជាស្អាត កម្ពុជាបៃតង។ ម្យ៉ាងវិញទៀត រដ្ឋបាលដែនដីត្រូវរៀបចំយន្តការអចិន្ត្រៃយ៍មួយ ដើម្បីសម្អាតអនាម័យតាមទីសាធារណៈ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ដោយប្រើប្រាស់មូលនិធិបានមកពីចំណូលផ្សេងៗក្នុងដែនដីរបស់ខ្លួន។
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវតាមដានការអនុវត្តជាក់ស្តែងរបស់បណ្តាក្រុមហ៊ុនវិនិយោគលើកោះ-ឆ្នេរ ដែលបានចុះកិច្ចសន្យារួចហើយ ដើម្បីធានាការអនុវត្តឱ្យបានស្របតាមគោលការណ៍កំណត់។ ចំពោះក្រុមហ៊ុនណាដែលពុំបានអនុវត្តគម្រោងតាមខ្លឹមសារកិច្ចសន្យាទេនោះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវលើកសំណើសុំលុបកិច្ចសន្យានោះចោល។

**២-ផ្នែកកម្មន្តសាល សហគ្រាសធុនតូច និងមធ្យម និងសេវា**

- ផ្តល់ជូនការលើកទឹកចិត្ត ដោយដាក់ជាបន្ទុករដ្ឋនូវអាករលើតម្លៃបន្ថែម ចំពោះការនាំចូលសរសៃសូត្រ សម្រាប់រយៈពេល២ឆ្នាំបន្ថែមទៀត រហូតដល់ដំណាច់ឆ្នាំ២០១៥តែម្តង ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំប្រកាសសម្រាប់ដាក់ឱ្យអនុវត្តនូវការសម្រេចផ្តល់ការលើកទឹកចិត្តនេះ។
- រាល់សហគ្រាសធុនតូច និងមធ្យម ត្រូវទៅចុះបញ្ជីនៅកន្លែងតែមួយគត់ គឺនៅលេខាធិការ-ដ្ឋានសហគ្រាសធុនតូច និងមធ្យម ក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត ស្របតាមខ្លឹមសារនៃសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៥៤៩ សជណ.សរ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៥ នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ។ ក្រសួងកសិកម្ម

រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងដទៃទៀត ត្រូវធ្វើប្រតិភូកម្មអំណាចរបស់ខ្លួនជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬចាត់វិធានការសមស្រប ដើម្បីចៀសវាងកុំឱ្យសហគ្រាសធុនតូច និងមធ្យមទៅបំពេញបែបបទនៅច្រើនកន្លែង ។ ដើម្បីឱ្យកិច្ចដំណើរការនេះមានប្រសិទ្ធភាព និងតម្លាភាព ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់វិធានការពង្រឹងយន្តការនៃលេខាធិការដ្ឋានសហគ្រាសធុនតូច និងមធ្យមឡើងវិញ រួមមាន÷

+ មន្ត្រីលេខាធិការដ្ឋានក្នុងក្របខ័ណ្ឌនៃស្ថាប័នច្រកចេញ-ចូលតែមួយ ត្រូវបំពេញភារកិច្ចផ្តល់សេវាជូនធុរជន និងវិនិយោគិន ក្នុងការទំនាក់ទំនងជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដើម្បីទទួលបាននូវរាល់ការយល់ព្រម ការអនុញ្ញាតចាំបាច់នានាពីក្រសួង-ស្ថាប័នទាំងនោះ ដោយពុំតម្រូវឱ្យធុរជន និងវិនិយោគិនទៅទំនាក់ទំនងផ្ទាល់ជាមួយក្រសួង-ស្ថាប័នណាមួយឡើយ។
+ កំណត់ពេលវេលាឆ្លើយតបនឹងសំណើរបស់ធុរជន និងវិនិយោគិនឱ្យបានច្បាស់លាស់។ រាល់ការយឺតយ៉ាវមិនបានឆ្លើយតបទាន់ពេលវេលាកំណត់នឹងត្រូវចាត់ទុកថាបានឯកភាព។

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវពិនិត្យសិក្សាលទ្ធភាព ផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារដល់ប្រភេទសហគ្រាសធុនតូច និងមធ្យមមួយចំនួន ក្នុងក្របខ័ណ្ឌនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ។

**៣-ផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច**

- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការអញ្ជើញធុរជនដែលមានអនុលោមភាពខ្ពស់ និងមានកិត្តិនាមល្បីៗ ដើម្បីផ្តល់ជូននូវសិទ្ធិជាប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាតតែម្តង ឱ្យបានមុនថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤។

**៤-ផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ**

- បង្កើតក្រុមការងារមួយដឹកនាំដោយធនាគារជាតិនៃកម្ពុជា ដោយមានការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ ដើម្បីរួមគ្នាពិនិត្យ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការជ្រើសរើសជម្រើសសម្រាប់អនុវត្តច្បាប់ FATCA ដែលជាច្បាប់ពន្ធដារថ្មីរបស់សហរដ្ឋអាមេរិក។

**៥-ផ្នែកដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ**

- ឯកភាពបញ្ចុះតម្លៃកម្រៃសេវាម៉ាស៊ីនស្កែនចំនួន២០%បន្ថែមទៀត ដោយក្នុងនោះ កម្រៃម៉ាស៊ីនស្កែន សម្រាប់កុងតែន័រ ៤០ហ្វីត នឹងត្រូវបញ្ចុះពី ៤០ មក ៣២ដុល្លាអាមេរិក ហើយសម្រាប់កុងតែន័រ ២០ហ្វីត នឹងត្រូវបញ្ចុះពី ២៥ មក ២០ដុល្លាអាមេរិក។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំបែបបទសម្រាប់ដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ តទៅ។ ជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវពិនិត្យពិចារណាសំណើរបស់ផ្នែកឯកជនដែលសុំប្តូរទីតាំងដាក់ម៉ាស៊ីនស្កែន នៅច្រកទ្វារបាវិត។

- ដើម្បីសម្រួលដល់ការនាំចេញស្រូវ-អង្ករនោះ រថយន្តធុនធំដឹកស្រូវ-អង្ករ ត្រូវបានអនុញ្ញាតឱ្យឆ្លងកាត់រាជធានីភ្នំពេញ ដោយចាត់ទុកថាជាករណីពិសេស។ ប៉ុន្តែ ដើម្បីធានាបាននូវការមិនកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញនោះ ចំពោះមុខនេះ ÷
    + សាលារាជធានីភ្នំពេញ ត្រូវរៀបចំធ្វើតម្រាយផ្លូវក្នុងរាជធានីភ្នំពេញ សម្រាប់អនុញ្ញាតិឱ្យរថយន្តធុនធំដឹកស្រូវ-អង្ករ ឆ្លងកាត់ ដោយមិនកំណត់ត្រឹមតែផ្លូវលេខ៣៧១ ឆ្លងកាត់ស្ពានព្រះមុនីវង្ស ទៅកំពង់ផែភ្នំពេញ LM17 ក្នុងឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ឡើយ ហើយត្រូវ កំណត់ពេលវេលាដែលត្រូវឆ្លងកាត់ឱ្យបានច្បាស់លាស់ គឺចន្លោះពីម៉ោង ១២ ដល់ម៉ោង ១៦ (តាមសំណូមពរផ្នែកឯកជន) ។
    + ក្រុមហ៊ុនដឹកជញ្ជូនត្រូវធ្វើការទំនាក់ទំនងជាមួយសាលារាជធានីភ្នំពេញ ដើម្បីទទួលបាននូវប័ណ្ណពិសេស សម្រាប់ធ្វើចរាចរឆ្លងកាត់តាមបណ្ដាផ្លូវដែលបានកំណត់ ហើយក្រុមហ៊ុនដែលបានទទួលការអនុញ្ញាតពិសេសនេះ ត្រូវអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ។

**៦-ផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម**

- ការត្រួតពិនិត្យទំនិញនាំចេញតាមរូបភាពគ្រប់គ្រងហានិភ័យ ត្រូវអនុវត្តចំពោះទំនិញនាំចេញទៅបណ្ដាប្រទេសដែលផ្ដល់ភាពអនុគ្រោះពន្ធនាំចូលទំនិញពីកម្ពុជាប៉ុណ្ណោះ ហើយការត្រួតពិនិត្យនេះទៀតសោធ ត្រូវអនុវត្តមិនលើសពី២% នៃចំនួនកុងតែន័រនាំចេញឡើយ។
- លើកទឹកចិត្តចំពោះការនាំចូលវត្ថុធាតុដើម និងធាតុចូលផ្សេទៀត សម្រាប់ឧស្សាហកម្មបម្រើឱ្យការនាំចេញកាបូប កាបូបយួរដៃ និងមួកព្រមទាំងផលិតផលប្រហាក់ប្រហែលមួយចំនួនទៀត ដូចគ្នា នឹងវិស័យកាត់ដេរ និងស្បែកជើង។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំប្រកាសសម្រាប់ដាក់ឱ្យអនុវត្តនូវការសម្រេចលើកទឹកចិត្តនេះ។

**៧-ផ្នែកស្រូវ-អង្ករ**

- បង្កើតសហព័ន្ធស្រូវ-អង្ករកម្ពុជា (ស.អ.ក) ដែលក្នុងនោះមាន សមាគម សហព័ន្ធអ្នកផលិត និងនាំអង្ករចេញ ព្រមទាំងអ្នកនាំអង្ករចេញទាំងអស់ សម្រាប់ធ្វើជាដៃគូដ៏សំខាន់របស់រាជរដ្ឋាភិបាល ក៏ដូចជាដៃគូរបស់សហព័ន្ធ ឬសមាគមស្រូវ-អង្ករ នៃបណ្ដាប្រទេសអាស៊ាន។ សហព័ន្ធស្រូវអង្ករកម្ពុជា ត្រូវចូលរួមជាមួយតំណាងរាជរដ្ឋាភិបាលក្នុងការចរចាតម្លៃ និងលក្ខខណ្ឌនានាជាមួយនឹងរដ្ឋាភិបាលក្រៅប្រទេស ដើម្បីជំរុញការនាំចេញអង្ករ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំប្រកាសដាក់ឱ្យប្រើប្រាស់នូវ÷
    + ការអនុវត្តអត្រាអាករលើតម្លៃបន្ថែម០% ចំពោះរោងម៉ាស៊ីនកិនស្រូវ ឬសហគ្រាសដែលប្រមូលទិញស្រូវយកមកធ្វើការកែច្នៃជាអង្ករ សម្រាប់ផ្គត់ផ្គង់បន្តឱ្យអ្នកនាំចេញ ដូចគ្នានឹងវិស័យកាត់ដេរដែរ។ ប៉ុន្តែសាមីសហគ្រាស ត្រូវលើកសំណើមកអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយនូវឯកសារគាំទ្រមួយចំនួន ដូចជា កិច្ចសន្យាផ្គត់ផ្គង់អង្ករ និងប្រតិវេទន៍តយជាដើម។
    + ការដាក់ជាបន្ទុករដ្ឋនូវអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់អង្ករ និងកន្ទក់ក្នុងស្រុក ។

ពាក់ព័ន្ធនឹងសំណូមពរមួយចំនួនទៀត ទាមទារឱ្យមានការសិក្សា និងការពិភាក្សាបន្ថែមទៀតរវាងផ្នែកឯកជន និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

ទទួលបានសេចក្តីជូនដំណឹងនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យទទួលបានលទ្ធផលជាវិជ្ជមាន។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

ចម្លងជូន÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន
- សមាជិកនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- សភាពាណិជ្ជកម្មរាជធានី ខេត្តពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ